ប្រស្នារកផល សំរាប់ ខ្មែរ ?

ប្រស្នារកផល[1] សំរាប់ ខ្មែរ នាបច្ចុប្បន្ន នេះ មិនមែន ឋិត នៅ លើ ការថ្កោលទោស របស់ សហគមន៏ អន្តរជាតិ ចំពោះ របប ក្រុងភ្នំពេញ នោះទេ ព្រោះ ទណ្ឌកម្ម នេះ វា ពិត ជា ផ្តល់ កម្ម វិបាក តែ មិនអាច ជា កម្លាំង សំរាប់ ប្តូរ របប ផ្តាច់ការ បាន នោះឡើយ។ ប្រស្នារកផល ពិត គឺ អត្តភាព នៃ កម្លាំង របស់ ប្រជានិករ និង សមត្ថភាព នៃ គណបក្ស ប្រឆាំង ប្រទល់នឹង កម្លាំងសមស្ត។ ត្រូវដឹង ថា ចាប់ ពី ឆ្នាំ ២០១២ វា មាន ពន្លឺ នៃ សេចក្តីសង្ឃឹម កើត មានឡើង ពី កំណើត នៃ គណបក្សស ង្គ្រោះជាតិ ដែល ជា កម្លាំង មូល របស់ ពួក អ្នកប្រជាធិបតេយ្យ គាំទ្រ ដោយ ពលរដ្ឋ ភាគច្រើន ផ្តល់ លទ្ធភាព អោយ មាន ប្រៀបលើ គណបក្ស កាន់អំណាច នៅក្នុង ការបោះឆ្នោត សាកល នៅ ឆ្នាំ ២០១៣។ ជ័យជំនះ នេះ បញ្ជាក់ អោយឃើញ ថា មាន ការរួមគ្នា រវាង គណបក្ស ប្រឆាំង តំណាង ប្រជាធិតី និង ឆន្ទានិសិទ្ធ របស់ ប្រជាពលរដ្ឋ។ អត្តភាព នេះ ជា មូលដ្ឋាន នៃ ក្តីសង្ឃឹម សកម្ម ដែល សង្ហូរ[2] អោយ យល់ ថា អំណាច ផ្តាច់ការ វា មិនដែល អមត: ឡើយ នៅ ចំពោះ គតិជាតិ របស់ ប្រជា ពលរដ្ឋ និង អ្នកប្រជាធិបតេយ្យ។ ដូច្នេះ ប្រស្នារកផល គឺ បន្ត ធ្វើ សកម្មភាព នៃ ក្តីសង្ឃឹម សកម្ម នេះ អោយ សម្រេច បាន៕

---

[1] ប្រស្នារកផល ពាក្យនេះ យើងយកមកប្រើ ក្នុងន័យ នៃ ពាក្យ បារាំង ថា enjeu។ សកម្មភាព មួយ ដែល អាច ឈ្នះ ឬ ចាញ់។

[2] សង្ហូរ : បណ្តាលឱ្យឃើញ ឬ ឱ្យយល់។

ឧប សៅ សន្ធា **គំនិត** **២៩ កុម្ភៈ ២០២០**